# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1308

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 10/01/20 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/25 |

៣. ចំណាយគម្រោងសរុប $67,500,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងអភិវឌ្ឍន៍ជនបទ

| | |
|---|---|
| RESPONSIBLE UNIT | Executive Agency |
| អង្គភាពទទួលខុសត្រូវ | ស្ថាប័នប្រតិបត្តិការគម្រោង |

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលគ្នារវាងឥណទាន និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

បញ្ចកោណទី៤- ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ នឹងផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋប្រហែល ៤៨០ ០០០ នាក់ ក្នុងខេត្តគោលដៅចំនួន៥ ដោយផ្តោតលើការបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋជាពិសេសក្រុមជនងាយរងគ្រោះនិងពលករចំណាកស្រុកដែលបានបាត់បង់ការងារដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ តាមរយៈផ្តល់ការងាររយៈពេលខ្លីក្នុងអំឡុងពេលអនុវត្តគម្រោង។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិវឌ្ឍន៍ជនបទ

Other

Other

Other

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ព្រៃវែង, ប៉ៃលិន, កោះកុង, ត្បូងឃ្មុំ , កំពង់ឆ្នាំង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលបំណងរបស់គម្រោងនេះ គឺជានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាពនូវសេដ្ឋកិច្ចជនបទ និងជីវភាពប្រជាជននៅតំបន់ជនបទដែលងាយរងគ្រោះ ព្រមទាំងប្រជាជនដែលត្រឡប់ពីចំណាកស្រុកដោយសារការប៉ះពាល់នៃការរីករាលដាលនៃជំងឺកូវីដ-១៩។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងបានហិរញ្ញប្បទានពីធនាគារ AIIB ដែលឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ក្នុងគោលបំណងដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ជនបទ បង្កើតការងារ ប្រាក់ចំណូល និងកសាងសមត្ថភាពប្រជាពលរដ្ឋក្នុងតំបន់គោលដៅ ព្រមទាំងពង្រឹងជំនាញក្រុមហ៊ុនទទួលការ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទដែលស្របទៅនឹងស្តង់ដារជាតិ។
(១)បង្កើនចំណេះដឹងរបស់ប្រជាពលរដ្ឋក្នុងតំបន់គោលដៅអំពីគម្លាតសង្គម និងការធ្វើអនាម័យ ដែលជាវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។ (២)ការត្រៀមលក្ខណៈនិងបង្កើនភាពធន់នឹងជំងឺនាពេលអនាគត។
គម្រោងមានសមាសភាគចំនួន២គឺៈ (១)ការវិនិយោគលើការអភិវឌ្ឍសេដ្ឋកិច្ចជនបទ រួមមានហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ និងផ្នែកទឹកស្អាត ការសំអាត និងអនាម័យជនបទ និង(២)ការអភិវឌ្ឍសមត្ថភាពជំនាញរបស់ក្រុមហ៊ុនម៉ៅការសាងសង់ និងប្រជាជនក្នុងតំបន់គោលដៅ ព្រមទាំងការងារគ្រប់គ្រងគម្រោងថ្នាក់កណ្តាល និងថ្នាក់ខេត្ត។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋតាមរយៈ៖
- ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ៖ (១)ស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រភេទ DBST និងប្រភេទផ្លូវបេតុងសរសៃដែកប្រវែងសរុប ២៣៥ គ.ម ព្រមទាំងសំណង់សិល្បការ្យពាក់ព័ន្ធនានា។ (២)កែលម្អស្ពាន លូ ប្រព័ន្ធរំដោះទឹក ដើម្បីសម្រួលការធ្វើដំណើររបស់ប្រជាពលរដ្ឋ ក្នុងមូលដ្ឋានឬពីកន្លែងមួយទៅកន្លែងមួយ រួមមានផ្សារ មន្ទីរពេទ្យ/មណ្ឌលសុខភាព និងសាលារៀន ព្រមទាំងតភ្ជាប់ទំនាក់ទំនងរវាងទីក្រុង -ជនបទក្នុងខេត្តក៏ដូចជារវាងខេត្ត-រាជធានី។ (៣) ការសាងសង់បានបញ្ចូលនូវវិធានការកាត់បន្ថយហានិភ័យដោយសារគ្រោះមហន្តរាយ រៀបចំតួផ្លូវ ដាំស្មៅ ដាំដើមឈើអមផ្លូវដោយប្រើប្រាស់ធនធានក្នុងតំបន់ ដើម្បីសម្រួលដល់ការដើរ និងជិះកង់ប្រកបដោយ សុវត្ថិភាព និងលើកកម្ពស់សុវត្ថិភាពផ្លូវជនបទ។
- ផ្នែកទឹកស្អាត និងអនាម័យ (១)ស្តារស្រះសហគមន៍ចំនួន ៧៥ ស្រះ ព្រមទាំងពង្រឹងគុណភាពស្រះសហគមន៍ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ (២)សាងសង់ស្រះសហគមន៍ថ្មីចំនួន ៧៥ ស្រះ លើកកម្ពស់អនាម័យជាពិសេសការអនុវត្តការលាងដៃជាវិធានការបង្ការជំងឺកូវីដ-១៩ ដល់ប្រជាពលរដ្ឋជនបទនិងកៀរគរសហគមន៍ដើម្បីចូលរួមប្រើប្រាស់ថែទាំ និងលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ទឹកប្រកបដោយសុវត្ថិភាពអនាម័យ ដែលជាការឆ្លើយតបបឋមនៃការរីរាលដាលនៃជំងឺកូវីដ១៩ ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

(១)ប្រជាពលរដ្ឋចំនួន ៥០,០០០ នាក់ ទទួលបានប្រាក់ចំណូលដោយផ្ទាល់បន្ថែមតាមរយៈការធ្វើផ្លូវក្នុងនាមជាកម្មករគ្មានជំនាញ

(២) ក្រុមហ៊ុនម៉ៅការសាងសង់ចំនួន ២៥ ក្រុមហ៊ុនទទួលបានការបណ្តុះបណ្តាលអំពីបច្ចេកទេស សាងសង់ ហេដ្ឋារចនាសម្ព័ន្ធជនបទសេវាមូលដ្ឋាន ចាំបាច់នានា និងវិធានការបង្ការជំងឺកូវីដ-១៩ (៣) ផ្លូវជនបទត្រូវបានកែលម្អដើម្បីសម្រួលការធ្វើដំណើរទៅកាន់ហេដ្ឋារចនាសម្ព័ន្ធនានាចំនួន១០០ទីតាំង រួមមានផ្សារ មន្ទីរពេទ្យ/មណ្ឌលសុខភាព និងសាលារៀន និង

(៤)ប្រជាពលរដ្ឋចំនួន ១៥០,០០០នាក់ ទទួលបានសេវាទឹកស្អាត និងអនាម័យកាន់តែប្រសើរឡើង ជាពិសេសវិធានការលាងសម្អាតដៃ ដែលជាវិធានការបឋមក្នុងការបង្ការជំងឺកូវីដ-១៩ ។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **ត្រូវបានបញ្ចប់**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងមិនប៉ះពាល់ដល់បរិស្ថាននិងការបណ្តេញចេញដោយមិនស្ម័គ្រចិត្តឬផលប៉ះពាល់ជាអវិជ្ជមានលើជនជាតិដើមភាគតិចនោះទេព្រោះគម្រោងបានរៀបចំផែនការយ៉ាងហ្មត់ចត់ដោយមានការពិគ្រោះយោបល់ជាសាធារណៈជាច្រើនលើកច្រើនសារស្របតាមគោលការណ៍នៃការដោះស្រាយផលប៉ះពាល់បរិស្ថាន និងសង្គមនិងធ្វើការសាងសង់តែលើផ្លូវជនបទដែលមានស្រាប់។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្ស៊ាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **៤. ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដោយបានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ** | 20 | **ទាក់ទងតិចតួច** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការកាត់បន្ថយ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងផ្តល់ឱកាសដូចៗគ្នារវាងបុរសនិងស្ត្រីក្នុងការទទួលបានការងារពេលសាងសង់ដោយទទួលបានប្រាក់កំរៃដូចគ្នា ដោយមិនរើសអើង ឬ ជនជាតិភាគតិច គម្រោងជម្រុញការចូលរួមរបស់ស្ត្រីក្នុងសកម្មភាព គម្រោងអោយបាន។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងអភិវឌ្ឍន៍ជនបទមានជំនាញ និងបទពិសោធន៍ក្នុងការអនុវត្តគម្រោងនេះ ។**

២៣. ស្ថានភាពនៃការអនុវត្តគម្រោង (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាល ឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

ក. ផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ
ឆ្នាំ២០២១:
• គម្រោងចាប់ផ្តើមដំណើរការជ្រើសរើសខ្សែផ្លូវកញ្ចប់ទី១ ក្នុងខេត្តចំនួន៣ ក្នុងចំណោមខេត្ត គម្រោង៥ ដើម្បីជួសជុលកែលម្អ និងមានប្រវែងសរុប ៣៧.៧៨៦ គ.ម។ ខេត្តកំពង់ឆ្នាំង មាន២ខ្សែ ផ្លូវប្រវែង ១៦.៨២៩គ.ម ខេត្តព្រៃវែងមាន១ខ្សែ ផ្លូវប្រវែង ១០.៦៧៩គ.ម និងខេត្តត្បូងឃ្មុំមាន១ខ្សែផ្លូវប្រវែង ១០.២៧៨ គ.ម ។
ឆ្នាំ ២០២២:
• គម្រោងចាប់ផ្តើមដំណើរការសាងសង់ខ្សែផ្លូវក្នុងកញ្ចប់ទី១ដែលបានជ្រើសរើសក្នុងឆ្នាំ ២០២១ ។
• គម្រោងចាប់ផ្តើមដំណើរការសិក្សាខ្សែផ្លូវក្នុងខេត្តគម្រោងទាំង៥ និងមានប្រវែងសរុប ១០៦.៩៩៧ គ.ម។
ខេត្តកំពង់ឆ្នាំងមាន២ខ្សែផ្លូវប្រវែង ៣២.៥២៥ គ.ម, ខេត្តព្រៃវែង មាន១ខ្សែផ្លូវប្រវែង ៨.០៦៤ គ.ម, ខេត្តត្បូងឃ្មុំមាន២ខ្សែផ្លូវប្រវែង ២៥.៧២១ គ.ម ខេត្តប៉ៃលិនមាន១ខ្សែផ្លូវប្រវែង ២០.៨៥០ គ.ម ខេត្តកោះកុងមាន១ខ្សែផ្លូវប្រវែង ១៩.៨៣៧ គ.ម។
ឆ្នាំ ២០២៣:
• គម្រោងបានបញ្ចប់ការសាងសង់ខ្សែផ្លូវក្នុងកញ្ចប់ទី១ដែលបានជ្រើសរើសក្នុងឆ្នាំ២០២១ 100% ប្រវែងសរុប ៣៧.៧៨៦ គ.ម។
• គម្រោងចាប់ផ្តើម និងកំពុងដំណើរការសាងសង់ខ្សែផ្លូវក្នុងកញ្ចប់ទី២ដែលបានជ្រើសរើស ក្នុងឆ្នាំ ២០២២ ។ លទ្ធផលសម្រេចបាន ៣៧.២៨ %។
• គម្រោងចាប់ផ្តើមដំណើរការសិក្សា និងរៀបចំឯកសារលទ្ធកម្មខ្សែផ្លូវសម្រាប់កញ្ចប់ទី៣ និងទី៤ ក្នុងខេត្តគម្រោងទាំង៥ចំនួន៨ខ្សែ និងមានប្រវែងសរុប ១២៤.៩៨៦ គ.ម។
កញ្ចប់ទី៣: ចំនួន៥ខ្សែ ក្នុងនោះខេត្តកំពង់ឆ្នាំង មាន១ខ្សែផ្លូវប្រវែង ៨.១៤០ គ.ម, ខេត្តព្រៃវែងមាន២ខ្សែផ្លូវប្រវែង ៣៣.៣២៨ គ.ម, ខេត្តត្បូងឃ្មុំមាន១ខ្សែផ្លូវប្រវែង ១២.៦៧០ គ.ម, និងខេត្តប៉ៃលិនមាន១ខ្សែផ្លូវប្រវែង ១៥.៣៣៨ គ.ម។
កញ្ចប់ទី៤: ចំនួន៣ខ្សែ ក្នុងនោះខេត្តព្រៃវែងមាន១ខ្សែផ្លូវប្រវែង ១៨.០៧៤ គ.ម ខេត្តត្បូងឃ្មុំមាន១ខ្សែផ្លូវប្រវែង ១១.២៣៦ គ.ម និងខេត្តកោះកុងមាន១ខ្សែផ្លូវប្រវែង ២៨.១០០ គ.ម។

ខ. ផ្នែកទឹកស្អាត សំអាត និងអនាម័យជនបទ
ការងារសាងសង់ស្រះសហគមន៍ គិតត្រឹមចុងឆ្នាំ២០២៣ នេះមានដូចតទៅ:
• កញ្ចប់ទី១: ស្រះសហគមន៍ចំនួន ៣៨ស្រះ ក្នុងខេត្តព្រៃវែង (១៦ស្រះ) កំពង់ឆ្នាំង (១០ស្រះ) និងខេត្តត្បូងឃ្មុំ (១២ស្រះ) ។ ការសាងសង់សម្រេចបាន ៤៧ %។
• កញ្ចប់ទី២: បានចុះសិក្សាទីតាំង ពិគ្រោះយោបល់ សិក្សាឋានលេខា និងបង្កើតក្រុមប្រើប្រាស់ទឹកនិងអនាម័យបានចំនួន ៤៣ ស្រះ (២៤ ស្រះ ក្នុងខេត្តកោះកុង និង ១៩ ស្រះ ក្នុងខេត្តប៉ៃលិន) ។
• កញ្ចប់ទី៣: បានចុះសិក្សាជំហ៊ានដំបូងចំនួន ២៩ស្រះនៅខេត្តកំពង់ឆ្នាំង ២០ស្រះនៅព្រៃវែង និង២៧ស្រះនៅត្បូងឃ្មុំ តាមសំណើពីអាជ្ញធរមូលដ្ឋាន។
ការងារបណ្តុះបណ្តាល:
• បណ្តុះបណ្តាល (TOT) ដល់មន្ត្រី PIU អំពីការផ្លាស់ប្តូរឥរិយាបទ និងការអនុវត្តការសំអាត និងអានាម័យ អ្នកចូលរួម ១០នាក់ (ស្រី ១នាក់)។
• បណ្តុះបណ្តាលទឹកស្អាតនិងអនាម័យដល់ប្រជាពលរដ្ឋក្នុងតំបន់គោលដៅ អ្នកចូលរួមចំនួន ១,២៧៨ នាក់ (ស្រី ៥១៩នាក់) ក្នុងខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង និងខេត្តត្បូងឃ្មុំ ។
• បណ្តុះបណ្តាលជនបង្គោល WUGS ដើម្បីក្លាយជាអ្នកសម្របសម្រួលថ្នាក់ភូមិ ស្តីពីទម្លាប់ល្អ ក្នុងការអនុវត្តអនាម័យជាប្រចាំ និងវិធីសាស្ត្រអប់រំដោយប្រើប្រាស់សម្ភារៈអប់រំផ្សព្វផ្សាយ (IEC materials) នៅខេត្តកំពង់ឆ្នាំង និងខេត្តព្រៃវែង ។ សរុបអ្នកចូលរួមចំនួន ៩០នាក់ (ស្រីចំនួន ២៨នាក់) ។

២៤. អាទិភាពរបស់គម្រោង (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្នើ | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 292,000.0 | 280,000.0 | 283,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 218,000.0 | 210,000.0 | 218,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 74,000.0 | 70,000.0 | 65,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 38,620,000.0 | 24,916,000.0 | 25,384,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 36,500,000.0 | 23,000,000.0 | 24,500,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 2,000,000.0 | 1,800,000.0 | 810,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 20,000.0 | 18,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 100,000.0 | 98,000.0 | 74,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 38,912,000.0 | 25,196,000.0 | 25,667,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 2,800,000.0 | 2,800,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 2,800,000.0 | 2,800,000.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 28,000,000.0 | 0.0 | 24,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ASEAN Infrastructure Investment Bank | 28,000,000.0 | 0.0 | 24,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 30,800,000.0 | 2,800,000.0 | 24,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 8,112,000.0 | 22,396,000.0 | 1,667,000.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: